**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកែប**
សំណុំរឿងព្រហ្មទណ្ឌលេខ ៧០ ចុះថ្ងៃទី
០៣ ខែកក្កដា ឆ្នាំ២០២៤
សាលក្រមព្រហ្មទណ្ឌលេខ ៨៤ "ឃ"
ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៤

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកែប

បានបើកសវនាការពិភាក្សាដេញដោលជាសាធារណៈ នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៤
វេលាម៉ោង ០៨ និង ៣០ នាទីព្រឹក ។

**សមាសភាពជំនុំជម្រះ**

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រម នៃសាលាដំបូងខេត្តកែប

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកែប

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកែប

**តុលាការ**

-**បានឃើញ**: ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ: ៦៣ អ.យ.ក/២៤ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០២៤ របស់អយ្យការអមសាលាដំបូងខេត្តកែប ។

-**បានឃើញ**: សំណុំរឿងជំនុំជម្រះផ្ទាល់លេខ: ៧៤ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកែប ។

-**បានឃើញ**: ចំណារចាត់តាំងចៅក្រមជំនុំជម្រះផ្ទាល់ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៤ របស់ប្រធានសាលាដំបូងខេត្តកែប ។

-**បានឃើញ**: ដីកាសម្រេចដាក់រឿងជំនុំជម្រះលេខ ៣៨២ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤ របស់ចៅក្រមជំនុំជម្រះនៃសាលាដំបូងខេត្តកែប ។

-**បានឃើញ**: ការផ្តល់ដំណឹងពីកាលបរិច្ឆេទនៃសវនាការតាមមាត្រា២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ: ៧០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៤ ដែលមានភាគី ៖

**ជនជាប់ចោទ**

ឈ្មោះ [redacted] **សំណាង** ភេទប្រុស កើតឆ្នាំ១៩៨១ ជនជាតិខ្មែរ មុខរបរតៃកុងឡាន កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពត មានអាសយដ្ឋានបច្ចុប្បន្ន

ស្ថិតនៅភូមិថ្កូវ ឃុំឬស្សីស្រុកខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត ឪពុកឈ្មោះ[redacted] មេន (រ) ម្ដាយឈ្មោះ[redacted] យ៉ូវ (ស) ប្រពន្ធឈ្មោះ [redacted] ឆាង មានកូនចំនួន ០២នាក់ កម្រិតវប្បធម៌រៀនថ្នាក់ទី៩ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការពីមុន (គ្មាន) ។

ជាប់ចោទពីបទ: **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ច នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក បណ្ដាលឲ្យរងរបួស និងស្លាប់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចភូមិកែវក្រសាំង សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៨៣ និងមាត្រា៨៥ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ។

## អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ឈ្មោះ [redacted] **ឫទ្ធិ** ភេទប្រុស អាយុ ៥៦ឆ្នាំ កើតឆ្នាំ១៩៦៧ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅភូមិព្រៃនប់២ ឃុំព្រៃនប់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។

## មេធាវីការពារសិទ្ធិឲ្យអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

លោកមេធាវី [redacted] ជាមេធាវីនៃក្រុមមេធាវី អេស វី អេស មានអាសយដ្ឋានស្ថិតនៅផ្លូវលេខ២១៣ ភូមិ១ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

## ដើមបណ្ដឹងរដ្ឋប្បវេណី

ឈ្មោះ [redacted] **តាំង** ភេទប្រុស ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរ អ្នកនេសាទ ទីកន្លែងកំណើតស្ថិតនៅភូមិស្វាយអន្លង់ ឃុំស្វាយអន្លង់ ស្រុកកំពង់ត្រាច ខេត្តកំពត មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅភូមិអំពេង ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប ឪពុកឈ្មោះ [redacted] ជ្រឹម (រ) ម្ដាយឈ្មោះ [redacted] លាង (រ) ប្រពន្ធឈ្មោះ [redacted] សារីម មានកូនចំនួន ០២នាក់ កម្រិតវប្បធម៌រៀនថ្នាក់ទី៧ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការពីមុន គ្មាន ។

ឈ្មោះ [redacted] **រឿន** ភេទស្រី ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ បុគ្គលិកកាស៊ីណូ មានទីកន្លែងកំណើតស្ថិតនៅភូមិអំពេង ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅភូមិអំពេង ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប ឪពុកឈ្មោះ [redacted] សិត (រ) ម្ដាយឈ្មោះ [redacted] ស៊ី (រ) ប្ដីឈ្មោះ [redacted] នឿន (ស) កម្រិតវប្បធម៌រៀនថ្នាក់ទី២ ប្រវត្តិនៃការផ្ដន្ទាទោសសដោយតុលាការពីមុន គ្មាន ។

## អង្គហេតុនៃបណ្ដឹងចោទប្រកាន់

កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោង ១៩.៣០នាទី មានករណី គ្រោះថ្នាក់ចរាចរណ៍មួយបានកើតឡើង រវាងរថយន្ត និងម៉ូតូ ទិសដៅបញ្ច្រាសគ្នា ពីលិចទៅកើត តាមផ្លូវជាតិលេខ៣៣ ត្រង់ចំណុចខាងកើតផ្លូវលំចូលវរសេនាតូចលេខ១ ចំការដូងចំហៀងខាងលិច ស្ថិតនៅភូមិកែវក្រសាំង សង្កាត់កែប ក្រុងកែប ខេត្តកែប ដែលបង្កឡើងដោយរថយន្ត ម៉ាកសាំយ៉ុង ពណ៌បៃតង ពាក់ស្លាកលេខ ភ្នំពេញ 2W-9780 បើកបរ ពីលិចទៅកើតដោយឈ្មោះ[redacted] **សំណាង** ភេទប្រុស អាយុ ៤៣ឆ្នាំ មកដល់ចំណុចកើតហេតុខាងលើ រថយន្តបង្កបានបុកម៉ូតូម៉ាក ហុងដា HONGDA CLICK ពណ៌ស ផលិតឆ្នាំ២០២១ ពាក់ស្លាកលេខ កែប 1B-7338 បើកបរពីលិចទៅកើត បណ្ដាលឲ្យឈ្មោះ [redacted] ងឿន ភេទប្រុស អាយុ ២៩ឆ្នាំ រងរបួសធ្ងន់ និងបានស្លាប់ពេលបញ្ជូនទៅដល់មន្ទីរពេទ្យវៀតណាម។ ដោយឡែកអ្នករួមដំណើរឈ្មោះ [redacted] តាំង ភេទប្រុស រងរបួសធ្ងន់ និងបានបញ្ជូនទៅមន្ទីរពេទ្យ ។

## នាពេលសវនាការ

កិច្ចជំនុំជម្រះបានចាប់ផ្ដើម ដោយចៅក្រមជំនុំជម្រះបានប្រកាសបើកសវនាការ និងបានឲ្យក្រឡាបញ្ជីធ្វើការរាយការណ៍អំពីវត្តមានចូលរួមរបស់ភាគី និងសាកសួរយោបល់របស់តំណាងអយ្យការ អំពីដំណើរការរឿងក្ដី-



Scanned with CamScanner

បន្ត។ ជាយោបល់របស់តំណាងអយ្យការ បានជូនយោបល់ និងស្នើសុំថា ខ្លួនសុំឲ្យមានការជំនុំជម្រះលើរឿងក្តីនេះ ទោះបីជាអវត្តមានជនជាប់ចោទ ៖

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] តាំង បានឆ្លើយបញ្ជាក់ថា៖ នៅថ្ងៃកើតហេតុ ខ្លួនជាមួយឈ្មោះ [redacted] ងឿន (ស្លាប់) បានបបួលគ្នាជិះម៉ូតូទៅរកអីហូបនៅខេត្តកំពត ដោយឈ្មោះ [redacted] ងឿន ជាអ្នកឌុបខ្លួន ដោយបានជិះចេញពីផ្ទះទៅក្នុងទិសដៅពីកើតទៅលិច លុះដល់ចំណុចម្តុំចំការដូង ក៏បានបុកជាមួយឡានមួយគ្រឿង ពេលនោះខ្លួនសន្លប់បាត់ស្មារតី ពុំបានដឹងខ្លួនអ្វីទៀតនោះទេ ។ លុះដល់ពេលដឹងខ្លួន គឺខ្លួននៅក្នុងមន្ទីរពេទ្យបាត់ទៅហើយ។ ខ្លួនពុំបានឃើញអ្វីនោះទេ មុនពេលកើតហេតុនោះ ។ ខ្លួនរងរបួសបែកក្បាល និងបាក់ជើងខាងស្តាំ ដោយបានព្យាបាលនៅមន្ទីរពេទ្យខ្មែរ និងវៀតណាម ចំណាយប្រាក់អស់ប្រហែល ១២,៤០០,០០០ (ដប់ពីរលានបួនសែន) រៀល។ ខ្លួនទទួលបានសំណង ៣,១០០ $ (បីពាន់មួយរយ) ដុល្លារអាមេរិក រួចហើយ។ ខ្លួនពុំទាមទារអ្វីទៀតទេ ពីជនបង្ក និងសុំបញ្ចប់រឿងត្រឹមណឹងចុះ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រឿន បានឆ្លើយបញ្ជាក់ថា៖ ប្តីរបស់ខ្លួនបានទទួលមរណភាពក្រោយពីគ្រោះថ្នាក់ចរាចរណ៍ ។ នៅថ្ងៃកើតេហតុនោះ ខ្លួនពុំបានដឹងរឿងអ្វីនោះទេ ព្រោះជាប់រវល់នៅកន្លែង-ការងារ ។ ខ្លួនបានទទួលសំណងរួចហើយ ពីជនបង្ក ចំនួន៣,១០០$ (បីពាន់មួយរយ) ដុល្លារអាមរិក។ ចំពោះម៉ូតូរបស់ប្តីខ្លួនជិះនោះ ម៉ាកហុងដា ឃ្លីច ពណ៌ស រងការខូចខាតច្រើន គឺនៅសល់តែម៉ាស៊ីនតែប៉ុណ្ណោះ ។ ខ្លួនបានយកម៉ូតូទៅជួសជុលអស់ប្រាក់ប្រហែលជា៧០០$ (ប្រាំពីររយ) ដុល្លារអាមេរិក ។ ខ្លួនពុំទាមទារអ្វីទៀតទេ ពីជនបង្ក និងសុំបញ្ចប់រឿងត្រឹមណឹងចុះ ។

-អ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុណ្ណា បានឆ្លើយបញ្ជាក់ថា៖ រថយន្តម៉ាកសាំយ៉ុងជារបស់ខ្លួននៅថ្ងៃកើតហេតុ ខ្លួនពុំបានដឹងរឿងអ្វីនោះទេ។ គ្រាន់តែខ្លួនបានដឹងថា តៃកុងឡានរបស់ខ្លួនឈ្មោះ [redacted] សំណាងភេទប្រុស ត្រូវជាប្អូនបង្កើតប្រុសរបស់ខ្លួន បានបើកឡានមកពីជួសជុលវិញ គឺបានប៉ះគ្នាជាមួយម៉ូតូមួយគ្រឿងក្រោយពីកើតហេតុ ខ្លួនក៏បានទៅមើលជនរងគ្រោះ និងបានសងសំណងទៅជនរងគ្រោះរួចរាល់ហើយ ។

-លោកវរៈសេនីយ៍ទោ [redacted] ម៉ុងគុល បានឆ្លើយបញ្ជាក់ថា៖ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោងប្រហែលជា ៩យប់ ខ្លួនទទួលបានការរាយការណ៍ពីមន្ត្រីនគរបាល ថាមានករណីគ្រោះថ្នាក់ចរាចរណ៍រវាងម៉ូតូ និងរថយន្ត។ ភ្លាមនោះខ្លួននិងមន្ត្រីជំនាញ ក៏បានចុះទៅដល់កន្លែងកើតហេតុស្ថិតនៅចំណុចភូមិកែវក្រសាំង សង្កាត់កែប ក្រុងកែប ខេត្តកែប ក៏បានឃើញម៉ូតូធ្លាក់ពីលើផ្លូវមកខាងឆ្វេង និងមានរងរបួសមនុស្សពីរនាក់ ចំណែករថយន្ត បានបើកចេញពីកន្លែងកើតហេតុប្រហែល ៣០ ម៉ែត្រ និងពុំមានម្ចាស់រថយន្តនៅកន្លែងកើតហេតុនោះទេ ។ ក្រោយពីឃើញជនរងគ្រោះដេកសន្លប់ពុំដឹងខ្លួន នៅពេលនោះសមត្ថកិច្ចយើងខ្ញុំក៏បានសួរនាំប្រជាពលរដ្ឋនៅក្បែរនោះ ដើម្បីរកសាច់ញាតិរបស់ជនរងគ្រោះទាំងពីរនាក់ និងបានទំនាក់ទំនងទៅសាច់ញាតិរបស់ជនរងគ្រោះ ព្រមទាំងជួយហៅឡានពេទ្យ ដើម្បីបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ ។ ដោយនៅពេលនោះសមត្ថកិច្ចពុំទាន់បានវាស់វែងនោះទេ ដោយសារគិតគូរជួយសង្គ្រោះជនរងគ្រោះផង ណាមួយពេលយប់ងងឹត និងនៅលើផ្លូវដែលជាកន្លែងកើតហេតុនោះ មានឡានបើកលឿនៗ ពិបាកក្នុងការបំពេញការងារ។ លុះព្រឹកទើបសមត្ថកិច្ចធ្វើការចុះវាស់វែងនៅកន្លែងកើតហេតុ និងបានសន្និដ្ឋានបានថា រថយន្តជាអ្នកខុស ។ ម្ចាស់រថយន្តក៏បានជួយព្យាបាល និងសងសំណងទៅជនរងគ្រោះរួចរាល់ហើយ ។

**សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ**

ក្រោយពីបញ្ចប់កិច្ចពិភាក្សាដេញដោលនាពេលសវនាការៈ តាមចម្លើយរបស់ជនរងគ្រោះ និងតាមការបំភ្លឺរបស់មន្ត្រីនគរបាលយុត្តិធម៌ ក៏ដូចជាការពិនិត្យភស្តុតាងដែលមានក្នុងសំណុំរឿង ឃើញថា៖ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ ពិតជាមានករណីគ្រោះថ្នាក់ចរាចរណ៍ រវាងរថយន្តសាំយ៉ុង និងម៉ូតូ ស្ថិតនៅចំណុច



Scanned with CamScanner

ភូមិកែវក្រសាំង សង្កាត់កែប ក្រុងកែប ខេត្តកែប ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ[redacted] សំណាង បើកបររថយន្តបណ្តាលឲ្យស្លាប់និងរងរបួសអ្នកដ៏ទៃ ដោយមានជនរងគ្រោះឈ្មោះ[redacted] ងឿន (ស្លាប់) និងជនរងគ្រោះឈ្មោះ [redacted] តាំង រងរបួសធ្ងន់ ពិតប្រាកដមែន។ ហេតុដូច្នេះ តំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ដូចក្នុងដីកាបញ្ជូនរឿងជំនុំជម្រះផ្ទាល់លេខ ៦៣ អ.យ.ក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤ ទុកដដែល និងស្នើសុំតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

**សេចក្តីសន្និដ្ឋានរបស់លោកមេធាវីការពារសិទ្ធិឲ្យអ្នកទទួលខុសត្រូវរដ្ឋប្បវេណី**

ក្រោយពីបញ្ចប់កិច្ចពិភាក្សាដេញដោលនាពេលសវនាការ ឃើញថា កូនក្តីរបស់ខ្លួនពុំមានជាប់ព័ន្ធ និងករណី បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឲ្យរងរបួស និងស្លាប់អ្នកដ៏ទៃ ស្ថិតនៅភូមិកែវក្រសាំង សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ នោះទេ ។ ម្យ៉ាងទៀត កូនក្តីរបស់ខ្លួនក៏បានសងសំណងរដ្ឋប្បវេណីទៅឲ្យក្រុមគ្រួសារជនរងគ្រោះរួចរាល់ហើយ រីឯជនរងគ្រោះក៏ពុំទាមទារអ្វីទៀតទេ និងដាក់ពាក្យសុំដកពាក្យបណ្តឹងវិញរួចហើយ ។ ហេតុដូច្នេះ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យឈ្មោះ[redacted] ប៊ុណ្ណា ស្នើសុំតុលាការសម្រេចកុំរឹបអូសរថយន្តរបស់កូនក្តីខ្លួន ព្រមទាំងស្នើសុំតុលាការកុំធ្វើការចោទប្រកាន់លើកូនក្តីរបស់ខ្លួន ។

## **សាលាដំបូង**

-ក្រោយពីបានស្តាប់ការបំភ្លឺរបស់មន្ត្រីនគរបាលយុត្តិធម៌

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានស្នើសុំរបស់មេធាវីការពារសិទ្ធិឲ្យអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យកស្តុតាងពាក់ព័ន្ធនានា ក្នុងសំណុំរឿងព្រហ្មទណ្ឌនេះ

-ក្រោយពីបានពិនិត្យយ៉ាងល្អិតល្អន់ និងពិចារណាយ៉ាងគ្រប់ជ្រុងជ្រោយ

## **សំអាងហេតុ**

តាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោលចំពោះមុខជាសាធារណៈ ដើម្បីស្វែងរកការពិតនៃសំណុំរឿងក្តីព្រហ្មទណ្ឌនេះ តាមរយៈការស្តាប់ចម្លើយរបស់ភាគីទាំងឡាយដែលពាក់ព័ន្ធ និងការពិនិត្យកស្តុតាងដែលបានស្វែងរកដោយមន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការ តុលាការយល់ឃើញថា៖

### **១.បណ្តឹងចោទប្រកាន់**

តំណាងអយ្យការ បានធ្វើការចោទប្រកាន់ និងបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លើជនជាប់ចោទ៖

-ឈ្មោះ[redacted] **សំណាង** ភេទប្រុស កើតឆ្នាំ១៩៨១ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ។

ពីបទ: **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ច នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក បណ្តាលឲ្យរងរបួស និងស្លាប់អ្នកដ៏ទៃ** ប្រព្រឹត្តនៅចំណុចភូមិកែវក្រសាំង សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៨៣ និងមាត្រា៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

### **២.ការវិនិច្ឆ័យចំពោះបទចោទប្រកាន់**

-តាមបញ្ញត្តិមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក បានចែងថា ៖

ជនណាបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរ-ណ៍ផ្លូវគោកតម្រូវ បណ្តាលឲ្យមានរបួសដល់អ្នកដ៏ទៃ ហើយបណ្តាលឲ្យអ្នករងគ្រោះអសមត្ថភាពធ្វើការងារក្នុង



Scanned with CamScanner

រយៈពេលស្មើ ឬលើសពី ៨ (ប្រាំបី) ថ្ងៃ គិតពីថ្ងៃកើតហេតុ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២(ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២,០០០,០០០ ៛ (ពីរលាន) រៀល ទៅ ១០,០០០,០០០៛ (ដប់លាន) រៀល និងអាចត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយ ឬច្រើនដូចមានចែងក្នុងមាត្រា៥៣ នៃក្រមព្រហ្មទណ្ឌ។

អំពើល្មើសខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ៤,០០០,០០០ ៛ (បួនលាន) រៀល ទៅ ១៥,០០០,០០០៛ (ដប់ប្រាំលាន) រៀល កាលបើអំពើនេះបានប្រព្រឹត្តក្នុងករណីណាមួយ [...] ។

-តាមបញ្ញត្តិមាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក បានចែងថា ៖

ជនណាបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវ បណ្តាលឲ្យស្លាប់អ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣(បី) ឆ្នាំ និងពិន័យជាប្រាក់ពី ៤,០០០,០០០ ៛ (បួនលាន) រៀល ទៅ ១៥,០០០,០០០៛ (ដប់ប្រាំលាន) រៀល និងអាចត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយ ឬច្រើនដូចមានចែងក្នុងមាត្រា៥៣ នៃក្រមព្រហ្មទណ្ឌ [...] ។

-តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ជាមន្ត្រីជំនាញចរាចរណ៍ បានបង្ហាញអោយឃើញថា៖ គ្រោះថ្នាក់ចរាចរណ៍មួយបានកើតឡើង កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោង០៩ និង ៣០ នាទី នៅលើផ្លូវជាតិលេខ៣៣ ចន្លោះបង្គោលគីឡូម៉ែត្រលេខ១៩.២០ ត្រង់ចំណុចខាងកើតផ្លូវលំចូលវរសេនាតូចលេខ១ ចំការដូងចំហៀងខាងលិចចម្ងាយ ៨៧.៥០ម៉ែត្រ ស្ថិតនៅភូមិកែវក្រសាំង សង្កាត់កែប ក្រុងកែប ខេត្តកែប ដោយបង្កឡើងដោយរថយន្តសាំយ៉ុង ពណ៌បៃតង ពាក់ស្លាកលេខភ្នំពេញ 2W-9780 បើកបរដោយឈ្មោះ [redacted] **សំណាង** ភេទប្រុស អាយុ ៤៣ឆ្នាំ បានបុកម៉ូតូម៉ាកហុងដា HONDA CLICK ពណ៌ស ផលិតឆ្នាំ២០២១ ពាក់ស្លាកលេខកែប 1B-7338 បណ្តាលឲ្យអ្នកបើកបរម៉ូតូឈ្មោះ [redacted] ងឿន ភេទប្រុស អាយុ ២៩ឆ្នាំ បានស្លាប់ពេលបញ្ជូនទៅមន្ទីរពេទ្យ និងអ្នករួមដំណើរឈ្មោះ [redacted] តាំង ភេទប្រុស អាយុ ២៩ឆ្នាំ រងរបួសធ្ងន់ (បែកក្បាល, បាក់ជើងខាងស្តាំ) ។

-តាមរបាយការណ៍បញ្ជូនលេខ ៩២៦ រ.ប.ក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤ របស់ស្នងការដ្ឋាននគរបាលខេត្តកែប បានធ្វើសេចក្តីសន្និដ្ឋានថា៖ *ករណីគ្រោះថ្នាក់ចរាចរណ៍នេះ គឺបង្កឡើងដោយរថយន្តសាំយ៉ុងពណ៌បៃតង ពាក់ស្លាកលេខភ្នំពេញ 2W-9780 បើកបរដោយឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ ៤៣ឆ្នាំ បើកបរមិនប្រកាន់ស្តាំបណ្តាលឲ្យបុកម៉ូតូម៉ាកហុងដា HONDA CLICK ពណ៌ស ផលិតឆ្នាំ២០២១ ពាក់ស្លាកលេខកែប 1B-7338 បើកបរដោយឈ្មោះ [redacted] ងឿន ភេទប្រុស (ស្លាប់) និងអ្នករួមដំណើរឈ្មោះ [redacted] តាំង ភេទប្រុស រងរបួសធ្ងន់ ។*

-តុលាការយល់ឃើញថា៖ សេចក្តីសន្និដ្ឋានរបស់មន្ត្រីជំនាញចរាចរណ៍ និងឆ្លងតាមការពិនិត្យភស្តុតាង និងចម្លើយភាគីពាក់ព័ន្ធទាំងឡាយ តុលាការយល់ឃើញថា ភាគីជនជាប់ចោទឈ្មោះ [redacted] **សំណាង** បានបើកបរដោយធ្វេសប្រហែស មិនប្រកាន់ស្តាំ ក៏បានបុកជាមួយម៉ូតូរបស់ជនរងគ្រោះបណ្តាលឲ្យឈ្មោះ [redacted] ងឿន (ស្លាប់) និងអ្នករួមដំណើរឈ្មោះ [redacted] តាំង រងរបួសធ្ងន់ ។

-តាមកំណត់ហេតុស្លាកស្នាមរងរបួសនៃជនរងគ្រោះថ្នាក់ចរាចរណ៍ និងកំណត់ហេតុត្រួតពិនិត្យជនរងគ្រោះថ្នាក់ចរាចរណ៍ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៤ របស់ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក បានបង្ហាញឲ្យឃើញថា៖

១-ឈ្មោះ [redacted] **ងឿន** ភេទប្រុស អាយុ២៩ឆ្នាំ ពាក់អាវយឺតដៃខ្លី ពណ៌សាច់ ស្លៀកខោជើងវែង ពណ៌ខ្មៅ មានរបួស៖ បែកថ្ងាសខាងឆ្វេង, បែកក្បាលលើត្រចៀកឆ្វេង រលាត់ស្បែកចង្កេះស្តាំ, រលាត់ស្បែកលើស្មាឆ្វេង,



Scanned with CamScanner

ហើមដាំលើដើមទ្រូងខាងឆ្វេង, របេកស្បែកលើពោះខាងស្តាំ, ហើមដាំលើខ្នងដៃស្តាំ, បាក់ភ្លៅខាងស្តាំ, ដាច់សាច់ជង្គង់ស្តាំ, បាក់ខ្នងជើងស្តាំ និងដាច់សាច់មេជើងស្តាំ (ស្លាប់)។

២-ឈ្មោះ [redacted] តាំង ភេទប្រុស អាយុ២៩ឆ្នាំ ពាក់អាវពណ៌ក្រហមដៃវែង ស្លៀកខោពណ៌ខ្មៅជើងវែង មានរបួស៖ ដាច់សាច់លើថ្ពាសខាងស្តាំ, ហើមដាំលើភ្នែកខាងស្តាំ, ដាច់សាច់ចង្ការ, របេកស្បែកថ្ពាល់ខាងឆ្វេង, បាក់ឆ្អឹងភ្លៅខាងស្តាំ, របេកស្បែកលើក្បាលជង្គង់ខាងឆ្វេង, របេកស្បែកខ្នងដៃឆ្វេង ។

-តាមកំណត់ហេតុស្លាកស្នាមខូចខាតយានជំនះដោយគ្រោះថ្នាក់ចរាចរណ៍ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៤ របស់អធិការដ្ឋាននគរបាលក្រុងកែប និងគំនូសស្នាម នៃគ្រោះថ្នាក់ចរាចរណ៍ គឺបានបង្ហាញអោយឃើញថា៖ ម៉ូតូរបស់ជនរងគ្រោះមានការខូចខាត និងគំនូសស្នាមទីតាំងនៃចំណុចដែលរថយន្តបុកម៉ូតូ គឺមានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់ភាគីពាក់ព័ន្ធបានឆ្លើយ ដែលសបញ្ជាក់ឲ្យឃើញ អំពីគ្រោះថ្នាក់ចរាចរណ៍ ដែលបង្កដោយភាគីខាងរថយន្តដែលបើកបរដោយឈ្មោះ [redacted] សំណាង ដោយការបើកបរខ្ជីខ្ជា មិនប្រុងប្រយ័ត្ន និងមិនគោរពច្បាប់ចរាចរណ៍ផ្លូវគោក ទើបបណ្តាលអោយមានអ្នករបួស និងអ្នកស្លាប់ ។

-ឆ្លងតាមកត្តាសត្យានុម័តនៃអំពើ និងសកម្មភាពរបស់ជនជាប់ចោទ ស្តែងចេញអោយឃើញ អំពីកត្តាអន្តោម័តរបស់ជនជាប់ចោទ ដែលគ្មានបំណងក្នុងការបង្កគ្រោះថ្នាក់ចរាចរណ៍នោះទេ ប៉ុន្តែប្រព្រឹត្តអំពើដោយអចេតនា ពោលគឺស្តែងចេញពីការធ្វេសប្រហែស ខ្ជីខ្ជា និងមិនប្រុងប្រយ័ត្ន ក្នុងបញ្ជាយានយន្តអោយបានត្រឹមត្រូវតាមបច្ចេកទេសបើកបរ និងច្បាប់ចរាចរណ៍ ។ ដូច្នេះអំពី និងសកម្មភាពខាងលើនេះ គឺច្បាប់ស្តីពីចរាចរណ៍ផ្លូវ-គោក បានចែង និងចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ដែលត្រូវតែផ្តន្ទាទោសទៅលើជនបង្កជាដាច់ខាត ។

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ បើធៀបទៅនឹងភស្តុតាងដោះបន្ទុក ដែលលើសពីវិមតិសង្ស័យទៅលើជនជាប់ចោទ ដូច្នេះមានពិរុទ្ធភាពគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] សំណាង ភេទប្រុស កើតឆ្នាំ១៩៨១ ជនជាតិខ្មែរ ពីបទៈ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ច នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក បណ្តាលឲ្យរងរបួស និងស្លាប់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចភូមិកែវក្រសាំង សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៨៣ និងមាត្រា៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

### ៣.ការវិនិច្ឆ័យចំពោះសេចក្តីសន្និដ្ឋានប្តឹងសុំ

-តំណាងអយ្យការប្តឹងសុំចៅក្រមជំនុំជម្រះ សម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

-លោកមេធាវីការពារសិទ្ធិឲ្យអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុណ្ណា បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំឲ្យតុលាការសម្រេចកុំរឹបអូសរថយន្ត និងស្នើសុំកុំធ្វើការចោទប្រកាន់លើឈ្មោះ [redacted] ប៊ុណ្ណា ។

-តាមបញ្ញត្តិមាត្រា ៣៣៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា៖ សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការមានមូលដ្ឋានត្រឹមត្រូវសមស្របទៅនឹងប្រយោជន៍ល្អនៃយុត្តិធម៌ គប្បីតុលាការពិចារណាតាមច្បាប់ ។

-គប្បី តុលាការពិចារណាទៅលើសេចក្តីសន្និដ្ឋានរបស់លោកមេធាវី ព្រមទាំងតំណាងអយ្យការ ដោយដោយផ្អែកទៅកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ដែលស្តែងឲ្យលេចចេញពីព្យសនកម្ម ទំហំនៃព្យសនកម្មដែលបានកើតឡើងលើជនរងគ្រោះ ។

### ៤.ការវិនិច្ឆ័យចំពោះសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ

ជនជាប់ចោទឈ្មោះ [redacted] **សំណាង** គឺជានីតិជនដែលមានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ ពោលគឺពុំមានភស្តុតាងណាមួយបញ្ជាក់ថាជននេះមានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទ ពិតជាមានស្មារតី-



Scanned with CamScanner

យល់ដឹងអំពីផលវិបាកដែលកើតចេញពីការប្រព្រឹត្តរបស់ខ្លួន ស្របតាមបញ្ញត្តិមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

### ៥.ការវិនិច្ឆ័យចំពោះទោស និងរបបប្រកាសទោស

#### ក.ចំពោះទោស

តុលាការពិចារណាលើកយកការសម្រេចទោសដាក់ពន្ធនាគារទៅលើជនជាប់ចោទ ដោយផ្អែកលើបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ មុន អំឡុងពេល និងក្រោយប្រព្រឹត្តអំពើល្មើស ដោយហេតុថា ជនជាប់ចោទបានចូលរួមសហការសួរបំភ្លឺនៅចំពោះមុខតំណាងអយ្យការ ។ ម្យ៉ាងទៀត ទំហំនៃព្យសនកម្ម ដែលកើតឡើងដោយសារការបើកបររថយន្តមិនប្រុងប្រយ័ត្នបណ្តាលឲ្យជនរងគ្រោះរងរបួស និងស្លាប់ ។ ដូច្នេះ គប្បីតុលាការសម្រេចទៅលើទោសដាក់ពន្ធនាគារ ក្នុងព្រំដែនដែលមាត្រា៨៣ និងមាត្រា៨៥ បានបញ្ញត្តិនិងចែងឲ្យផ្តន្ទាទោស។

#### ខ.ចំពោះរបបប្រកាសទោស

-តាមមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៨៣ និងមាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក នៃព្រះរាជាណាចក្រកម្ពុជា តុលាការសម្រេចយកការប្រកាសមូលទោស ដោយការផ្តន្ទាទោសដាក់ពន្ធនាគារ។

-ចំពោះ ទោសដាក់ពន្ធនាគារ តុលាការសម្រេចយកការព្យួរទោសទាំងមូលមកអនុវត្តលើជនជាប់ចោទ ដោយប្រកាសទោសដាក់ពន្ធនាគាររយៈពេល ០១(មួយ) ឆ្នាំ ដោយព្យួរការអនុវត្តទោសធម្មតាទាំងមូល តាមមាត្រា ១០៤ ដល់មាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ដោយហេតុថានេះគឺជាគ្រោះថ្នាក់ចរាចរណ៍ដែលគ្មានភាគីខាងណាចង់អោយកើតមានឡើងនោះទេ ហើយអ្នកទទួលខុសត្រូវរដ្ឋប្បវេណីក៏បានសងសំណងទៅជនរងគ្រោះរួចហើយដែរ និងជនរងគ្រោះក៏ព្រមទទួលយក ដោយបានធ្វើកិច្ចព្រមព្រៀង និងលិខិតមិនប្តឹងតវ៉ាផងដែរ ។

### ៦.ការវិនិច្ឆ័យចំពោះវត្ថុចាប់យក

-វត្ថុចាប់យក ដែលត្រូវបានដកហូតដោយមន្ត្រីនគរបាលយុត្តិធម៌ រួមមាន: រថយន្តសាំយ៉ុង ពណ៌បៃតង ផលិតឆ្នាំ២០០០ ពាក់ស្លាកលេខភ្នំពេញ 2W-9780 និងម៉ូតូម៉ាកហុងដា HONDA CLICK ពណ៌ស ផលិតឆ្នាំ២០២១ ពាក់ស្លាកលេខកែប 1B-7338 ដូចមានក្នុងកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៤ ។

-យោងតាមដីកាបង្គាប់ឲ្យប្រគល់វត្ថុចាប់យកឲ្យទៅម្ចាស់ដើមវិញលេខ ២២ អ.យ.ក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៤ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកែប ។ វត្ថុចាប់យកខាងលើនេះត្រូវបានតំណាងអយ្យការអមសាលាដំបូងខេត្តកែប ប្រគល់ឲ្យម្ចាស់ដើមវិញរួចរាល់ គប្បីតុលាការមិនលើកយកមកពិចារណា និងសម្រេចនោះឡើយ។

### ៧.ការវិនិច្ឆ័យចំពោះសំណងរដ្ឋប្បវេណី

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] តាំង និងឈ្មោះ [redacted] វឿន បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពុំបានទាមទារសំណងរដ្ឋប្បវេណីនោះទេ ព្រោះដើមបណ្តឹងរដ្ឋប្បវេណីបានទទួលសំណងក្នុងម្នាក់ចំនួន៣,១០០$ (បីពាន់មួយរយ) ដុល្លារអាមេរិក រួចហើយ។ ហេតុដូច្នេះ គប្បីតុលាការមិនលើកយកមកសម្រេចជាថ្មីនោះទេ។

**វិនិច្ឆ័យសេចក្តី**

**ហេតុដូច្នេះសម្រេច**

-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **សំណាង** ភេទប្រុស កើតឆ្នាំ១៩៨១ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ)ឆ្នាំ ប៉ុន្តែព្យួរការអនុវត្តទោសធម្មតា ។



Scanned with CamScanner

ពីបទៈ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ច នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក បណ្តាលឲ្យរងរបួស និងស្លាប់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចភូមិកែវក្រសាំង សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨៣ និងមាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៤ ចាត់ទុកចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សំណាង** ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខានិងត្រា-[redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខានិងត្រា-[redacted]

---

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃព្រហស្បតិ៍ ៥កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស២៥៦៨
ខេត្តកែប, ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៤
**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ
**ចៅក្រមជំនុំជម្រះ**

[redacted]